ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(គ.ជ.ប)

# សំណួរ_ចម្លើយ

ស្ដីពី

## ការស្វែងយល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

(ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩)

# មាតិកា

**ទំព័រ**


សំណួរទី១ : តើក្រុមប្រឹក្សាមានអាណត្តិប៉ុន្មានឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលណា ? .................... ១

សំណួរទី២ : តើសមាជិកក្រុមប្រឹក្សា ត្រូវជ្រើសរើសឡើងយ៉ាងដូចម្តេច ? .................................... ១

សំណួរទី៣ : តើក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌមានចំនួនសមាជិកប៉ុន្មានរូប ?................ ២

សំណួរទី៤ : តើស្ថាប័នណាជាអ្នកកំណត់ចំនួននៃសមាជិកក្រុមប្រឹក្សានីមួយៗ ? .................................. ២

សំណួរទី៥ : តើចំនួនអាសនៈសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី៣ សរុបទូទាំងប្រទេសមានចំនួនប៉ុន្មាន ? ........................................... ៣

សំណួរទី៦ : តើចំនួនអាសនៈសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ សរុបទូទាំងប្រទេសមានចំនួនប៉ុន្មាន ? ...................................... ៣

សំណួរទី៧: តើស្ថាប័នណាជាអ្នកកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?.......... ៣

សំណួរទី៨ : តើកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ប្រព្រឹត្តទៅនៅពេលណា ?............................................. ៣

សំណួរទី៩ : តើស្ថាប័នណា ជាអ្នកគ្រប់គ្រងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ?................................ ៤

សំណួរទី១០ : តើមណ្ឌលបោះឆ្នោតសម្រាប់បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាមានទីតាំងនៅកន្លែងណា ?. ៤

សំណួរទី១១ : ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សា តើប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទត្រូវមានលក្ខខណ្ឌ និងលក្ខណៈសម្បត្តិអ្វីខ្លះ ? ........................................ ៤

សំណួរទី១២ : តើអ្នកណាខ្លះ ដែលគ្មានសិទ្ធិឈរឈ្មោះជា បេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?....... ៥

សំណួរទី១៣: តើមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការនគរបាលជាតិ កងយោធពលខេមរភូមិន្ទមន្ត្រីបុគ្គលិក របស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើយ៉ាង ដូចម្តេចដើម្បី អាចឈរឈ្មោះជាបេក្ខជន បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?.................. ៦

សំណួរទី១៤: តើគណបក្សនយោបាយដែលមានបំណង ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាត្រូវចាប់ផ្តើមដាក់ពាក្យ សុំចុះបញ្ជី គណបក្សនយោបាយឈរឈ្មោះ បោះឆ្នោត នៅគជ.ខបយ៉ាងតិចប៉ុន្មានថ្ងៃមុន កាលបរិច្ឆេទនៃការបោះឆ្នោត? ....................... ៨

សំណួរទី១៥: តើនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីគណបក្ស នយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សា ត្រូវធ្វើយ៉ាងដូចម្ដេច ? .................... ៨
សំណួរទី១៦: តើការចុះបញ្ជីគណបក្សនយោបាយឈរ
ឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមាន
រយៈពេលប៉ុន្មានថ្ងៃ ហើយត្រូវដាក់ពាក្យសុំចុះ
បញ្ជីនៅកន្លែងណា? ........................................ ៨
សំណួរទី១៧: បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវ
បានដាក់ពាក្យសុំចុះបញ្ជីនៅគជ.ខបរួចហើយ
តើបេក្ខជនអាចសុំលាឈប់ ឬប្ដូរបេក្ខជន
ឬដកបញ្ជីបេក្ខជនឈរឈ្មោះបានដែរឬទេ ? ... ៩
សំណួរទី១៨: តើបេក្ខជនម្នាក់អាចមានឈ្មោះក្នុងបញ្ជីបេក្ខជន
នៃគណបក្សនយោបាយលើសពីមួយបានដែរ
ឬទេ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់
ក្រុមប្រឹក្សាលើសពីមួយ បានដែរឬទេ ?......... ១០
សំណួរទី១៩: តើការឃោសនាបោះឆ្នោតមានទិសដៅអ្វី ? ...១០
សំណួរទី២០: ដូចម្ដេចដែលហៅថាការឃោសនាបោះឆ្នោត?.. ១០
សំណួរទី២១: តើសកម្មភាពឃោសនាបោះឆ្នោតជ្រើសរើស
ក្រុមប្រឹក្សាត្រូវធ្វើឡើងក្នុងរយៈពេលប៉ុន្មានថ្ងៃ?
ចាប់ពីថ្ងៃណា ដល់ថ្ងៃណា? .......................... ១០
សំណួរទី២២: តើសកម្មភាពឃោសនាបោះឆ្នោតរបស់
គណបក្សនយោបាយត្រូវចាប់ផ្ដើមពីម៉ោង
ប៉ុន្មាន ដល់ម៉ោងប៉ុន្មាន? .............................. ១១
សំណួរទី២៣: តើសកម្មភាពឃោសនាដោយឧបករណ៍បំពង
សំឡេងត្រូវបានហាមឃាត់ នៅពេលណាខ្លះ

និងនៅកន្លែងណាខ្លះ? ............................................ ១២
សំណួរទី២៤: តើអ្នកណាជាអ្នកបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា ? ................................................................ ១២
សំណួរទី២៥: តើ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោត សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលប៉ុន្មានថ្ងៃ មុនថ្ងៃបោះឆ្នោត ? ... ១២
សំណួរទី២៦: បញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាដែល គ.ជ.ប បានផ្តល់ សុពលភាពរួចហើយ តើអាចកែប្រែបាន ដែរឬទេ? ........................................................ ១២
សំណួរទី២៧: តើការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើនៅ ពេលណា និងនៅកន្លែងណា ? ..................... ១៣
សំណួរទី២៨: ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបាន តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខ តំណែង ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ................ ១៣
សំណួរទី២៩: តើឯកសារបញ្ជាក់អត្តសញ្ញាណ ដែល គ.ជ.ប កំណត់ដើម្បីប្រើប្រាស់ក្នុងពេល បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា មានអ្វីខ្លះ ?................. ១៤
សំណួរទី៣០: តើការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យ បោះឆ្នោត សម្រាប់ការបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សាត្រូវធ្វើនៅកន្លែងណាខ្លះ និងនៅ ពេលណា ? ........................................................ ១៤

សំណួរទី៣១: នៅថ្ងៃបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ
សង្កាត់ នៅក្នុងមុខតំណែងណាដែលគ្មាន
ឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការតើមានសិទ្ធិ
បោះឆ្នោតបានដែរឬទេ?................................ ១៥
សំណួរទី៣២: តើអ្នកបោះឆ្នោតអាចឱ្យអ្នកផ្សេងបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាជំនួសខ្លួនបានដែរឬទេ? ..១៥
សំណួរទី៣៣: តើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវ
ចាប់ផ្តើមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?....... ១៥
សំណួរទី៣៤: នៅថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តើអ្នក
បោះឆ្នោតណាខ្លះដែលត្រូវបាន ផ្តល់អាទិភាព
ចូលក្នុងការិយាល័យបោះឆ្នោតមុនគេ ?........ ១៦
សំណួរទី៣៥: តើអ្នកបោះឆ្នោតម្នាក់ៗ មានសិទ្ធិបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាណាខ្លះ ហើយអ្នក
បោះឆ្នោត ត្រូវធ្វើដូចម្តេចខ្លះសម្រាប់ការ
បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?................ ១៦
សំណួរទី៣៦: តើអ្នកបោះឆ្នោតអាចស្នើសុំជំនួយពីជនណា
ម្នាក់ ដែលមានវត្តមានក្នុង ការិយាល័យ
បោះឆ្នោតឱ្យជួយគាត់ក្នុងការបោះឆ្នោតបាន
ដែរឬទេ?................................................ ១៨
សំណួរទី៣៧: ប្រសិនបើអ្នកបោះឆ្នោតជាជនមានពិការភាព
មិនអាចបោះឆ្នោត ដោយខ្លួនឯងបាន តើគាត់
ត្រូវធ្វើដូចម្តេចដើម្បីបោះឆ្នោតបាន?............. ១៨

សំណួរទី៣៨: តើភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោតអាចជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានដែរឬទេ? .............................. ១៨
សំណួរទី៣៩: តើអ្នកបោះឆ្នោត ឬអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចប្រើទូរស័ព្ទដៃ ឬឧបករណ៍ ផ្សេងៗដែលអាចថតរូបបានដែរឬទេ? .............................................................. ១៩
សំណួរទី៤០: តើកាលបរិច្ឆេទនៃការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រព្រឹត្តទៅនៅពេលណា ?............................ ១៩

# អារម្ភកថា

កូនសៀវភៅសំណួរ-ចម្លើយនេះរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងគោលបំណងផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ពិសេសដល់អ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែង អំពីចំណុចសំខាន់ៗពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩។

ខ្លឹមសារ សំណួរ ចម្លើយ គឺបានដកស្រង់ចេញពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

កូនសៀវភៅនេះ គឺជាជំនួយស្មារតីខ្លះៗដល់មិត្តអ្នកអាន។ ប្រសិនបើចង់ស្វែងយល់ ឱ្យកាន់តែច្បាស់អំពីព័ត៌មាននានាពាក់ព័ន្ធទៅនឹងដំណើរការនៃការរៀបចំការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩ មិត្តអ្នកអានអាចរកបានតាមរយៈគេហទំព័រ គ.ជ.ប www.necelect.org.kh។

សូមអរគុណ!

# សំណួរ-ចម្លើយ
# ស្តីពី
# ការស្វែងយល់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

ចំណាំ : ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហៅកាត់ថា "ក្រុមប្រឹក្សា"

សំណួរ១ : តើក្រុមប្រឹក្សាមានអាណត្តិប៉ុន្មានឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលណា ?

ចម្លើយ : ក្រុមប្រឹក្សាមានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។

សូមបញ្ជាក់ថា មាត្រា ១៦ ក្នុងពេលរងចាំក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិ មានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ។

សំណួរ២: តើសមាជិកក្រុមប្រឹក្សា ត្រូវជ្រើសរើសឡើងយ៉ាងដូចម្តេច ?

ចម្លើយ : សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសឡើងដោយការបោះឆ្នោតអសកល មិនចំពោះដោយ សេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើស ឆ្នោតជាសម្ងាត់។

សំណួរ៣: តើក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកប៉ុន្មានរូប ?

ចម្លើយ : អនុលោមតាមមាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច.គ.ខ.ស) ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តា ប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពី ២៧រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពី ១៥រូប ដល់ ២៧រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពី ១១រូប ដល់ ២១រូប
- ក្រុមប្រឹក្សាស្រុក ខណ្ឌ មានចំនួនសមាជិកពី ១១រូប ដល់ ២១រូប។

សំណួរ៤: តើស្ថាប័នណាជាអ្នកកំណត់ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ?

ចម្លើយ : ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងតិច ១២០ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។

សំណួរ៥: តើចំនួនអាសនៈសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី៣ សរុបទូទាំងប្រទេសមានចំនួនប៉ុន្មាន ?

ចម្លើយ : ចំនួនអាសនៈសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី៣ សរុបទូទាំងប្រទេសមាន ចំនួន ៥៥៩រូប។

សំណួរ៦: តើចំនួនអាសនៈសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ សរុបទូទាំងប្រទេស មានចំនួនប៉ុន្មាន ?

ចម្លើយ : ចំនួនអាសនៈសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៣ សរុបទូទាំងប្រទេស មានចំនួន ៣.៥៥៥រូប។

សំណួរ៧: តើស្ថាប័នណាជាអ្នកកំណត់កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៣ ?

ចម្លើយ : កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ត្រូវកំណត់ដោយ នាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សំណួរ៨: តើកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៣ ប្រព្រឹត្តទៅនៅពេលណា ?

ចម្លើយ : កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី២៦ ខែឧសភា ឆ្នាំ២០១៩។

សំណួរ៩: តើស្ថាប័នណាជាអ្នកគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?

ចម្លើយ: ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

សំណួរ១០: តើមណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានទីតាំងនៅកន្លែងណា ?

ចម្លើយ: មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារួមមាន៖

- រាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត
- ក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

សំណួរ១១: ដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតើប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវមានលក្ខខណ្ឌ និងលក្ខណសម្បត្តិអ្វីខ្លះ ?

ចម្លើយ : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិច ២៥ឆ្នាំគិតមកដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

សំណួរ១២: តើអ្នកណាខ្លះដែលគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?

ចម្លើយ : មាត្រា១៧ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើស-រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចែងថា៖

អ្នកគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មាន៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និង ចៅក្រម
- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិលមន្ត្រីតុលាការកងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង
- មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់
- ជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ណាមួយ ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ជនវិកលចរិក ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលមានលិខិតបញ្ជាក់ ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប
- ព្រះសង្ឃ ឬ បព្វជិតសាសនា។

សំណួរ១៣: តើមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីអាចឈរឈ្មោះជាបេក្ខជន បោះឆ្នោត

ជ្រើសរើសក្រុមប្រឹក្សា ?

ចម្លើយ : មាត្រា ១៨នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌចែងថា៖

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការនគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (៧)ថ្ងៃ មុនថ្ងៃ បើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត ហើយមានបំណងចង់បម្រើការងារជាសមាជិកក្រុម ប្រឹក្សានោះ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬស្ថាប័នសាមី ដើម្បីទៅ បម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួល សោធននិវត្តន៍។

នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចសុំត្រឡប់មកបម្រើការងារ នៅក្រសួង ឬស្ថាប័នដើមវិញ ប៉ុន្តែមុខងារ និងតំណែង

អាស្រ័យដោយក្រសួង ឬស្ថាប័ន ជាអ្នកសម្រេច។

សំណួរ១៤: តើគណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្ដើមដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅគធ.ខប យ៉ាងតិចប៉ុន្មានថ្ងៃមុនកាលបរិច្ឆេទនៃការបោះឆ្នោត ?

ចម្លើយ : គណបក្សនយោបាយ ដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្ដើមដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) យ៉ាងតិច ៨០ថ្ងៃ មុនកាលបរិច្ឆេទនៃការបោះឆ្នោត ។

សំណួរ១៥: តើនីតិវិធីនៃការ ដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើយ៉ាងដូចម្ដេច ?

ចម្លើយ : គណបក្សនយោបាយដែលមានបំណងចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួន តាមមណ្ឌលបោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗដោយឡែកពីគ្នា។

សំណួរ១៦: តើការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ

បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានរយៈពេលប៉ុន្មានថ្ងៃ ហើយត្រូវដាក់ពាក្យសុំចុះបញ្ជីនៅកន្លែងណា ?

ចម្លើយ : ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គណបក្សនយោបាយត្រូវដាក់ពាក្យសុំតាមបែបបទកំណត់ដោយ គ.ជ.ប ទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ក្នុងរយៈពេល ៥ថ្ងៃ ចាប់ផ្ដើមពីថ្ងៃទី០៧ ខែមីនា ដល់ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០នាទី ដល់ម៉ោង៥:៣០នាទី។

សំណួរ១៧: បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនៅ គធ.ខប រួចហើយ តើបេក្ខជនអាចសុំលាឈប់ ឬប្ដូរបេក្ខជន ឬដកបេក្ខជនឈរឈ្មោះបានដែរឬទេ ?

ចម្លើយ : បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនៅ គធ.ខប រួចហើយ មិនអនុញ្ញាតឲ្យបេក្ខជនលាឈប់ឬប្ដូរបេក្ខជន ឬដកបេក្ខជនឈរឈ្មោះឡើយ។ បេក្ខជនអាចលាឈប់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយបានបន្ទាប់ពី គធ.ខប ទទួលស្គាល់ជា

ផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរ ឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។

សំណួរ១៨: តើបេក្ខជនម្នាក់អាចមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយបានដែរឬទេ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយបានដែរឬទេ?

ចម្លើយ: បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយឬឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប។

សំណួរ១៩: តើការឃោសនាបោះឆ្នោតមានទិសដៅអ្វី ?

ចម្លើយ : ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណ-បក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត។

សំណួរ២០: ដូចម្តេចដែលហៅថា ការឃោសនាបោះឆ្នោត?

ចម្លើយ : ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

សំណួរ២១: តើសកម្មភាពឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងក្នុងរយៈពេលប៉ុន្មាន

ថ្ងៃ ? ចាប់ពីថ្ងៃណា ដល់ថ្ងៃណា ?

ចម្លើយ : សកម្មភាពឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងក្នុងរយៈពេល ៨ថ្ងៃជាប់ៗគ្នា គឺចាប់ពីថ្ងៃទី១៧ រហូតដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩។

សំណួរ២២: តើសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

ចម្លើយ: គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦:០០នាទីព្រឹក ដល់ម៉ោង ១០:០០នាទីយប់ និងត្រូវឈប់សម្រាកចាប់ពីម៉ោង ១០:០០នាទីយប់ ដល់ម៉ោង ៦:០០នាទីព្រឹក។

សំណួរ២៣: តើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវបានហាមឃាត់នៅពេលណា ខ្លះ និងនៅកន្លែងណាខ្លះ?

ចម្លើយ : សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២:០០នាទីថ្ងៃត្រង់ ដល់ម៉ោង ២:០០នាទីរសៀល។
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

សំណួរ២៤: តើអ្នកណាជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?

ចម្លើយ : អ្នកមានសិទ្ធិបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែង នៅក្នុងក្រុបខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ។

សំណួរ២៥: តើ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងរយៈពេលប៉ុន្មានថ្ងៃ មុនថ្ងៃបោះឆ្នោត ?

ចម្លើយ : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោត។

សំណួរ២៦: តើបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែល គ.ជ.ប បានផ្តល់សុពលភាពរួចហើយ អាចកែប្រែបានដែរឬទេ?

ចម្លើយ: បញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែល គ.ជ.ប បានផ្តល់សុពលភាពរួចហើយ មិនអាចកែប្រែបានទេលើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព។ ក្នុងករណីមានសមាជិកក្រុម ប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ទទួលមរណភាពក្រសួងមហាផ្ទៃត្រូវបំពេញបែបបទ

ផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេល ៧ថ្ងៃ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជំនួស ក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

សំណួរ២៧: តើការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើនៅពេលណា និងនៅកន្លែងណា ?

ចម្លើយ : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងនៅកន្លែងសាធារណៈណាមួយក្នុងមណ្ឌលបោះឆ្នោតតាមប្រភេទ ក្រុមប្រឹក្សា។

សំណួរ២៨: ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបាន តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ?

ចម្លើយ : ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានសមា-ជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែងត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបង្ហាញដល់មន្ត្រីការិយាល័យបោះឆ្នោត នូវឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនតាមការកំណត់របស់ គ.ជ.ប។

សំណួរ២៩: តើឯកសារបញ្ជាក់អត្តសញ្ញាណដែល គ.ជ.ប កំណត់ ដើម្បីប្រើប្រាស់ក្នុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានអ្វីខ្លះ ?

ចម្លើយ : ឯកសារបញ្ជាក់អត្តសញ្ញាណដែល គ.ជ.ប កំណត់ដើម្បីប្រើប្រាស់ក្នុងពេលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាមាន៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលនៅមានសុពលភាព ឬ
- លិខិតសម្គាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែង ឬ
- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ដែលចេញដោយមេឃុំ ចៅសង្កាត់។

សំណួរ៣០: តើការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើនៅកន្លែងណាខ្លះ និងនៅពេលណា ?

ចម្លើយ : ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើនៅតាមសាលាឃុំ សង្កាត់ និងនៅតាមទីសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត។

សំណួរ៣១: នៅថ្ងៃបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែងណាដែលគ្មានឈ្មោះក្នុង បញ្ជីបោះឆ្នោតផ្លូវការ តើមានសិទ្ធិបោះឆ្នោត បានដែរឬទេ?

ចម្លើយ : នៅថ្ងៃបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែងណាដែលគ្មានឈ្មោះ ក្នុងបញ្ជី បោះឆ្នោតផ្លូវការ ទោះបីមានអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ (អ.ខ) ឬលិខិតសម្គាល់ខ្លួនជាសមាជិក ក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងមុខតំណែង ឬឯកសារ បញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ក៏ដោយក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ។

សំណួរ៣២: តើអ្នកបោះឆ្នោតអាចឱ្យអ្នកផ្សេងបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាជំនួសខ្លួនបានដែរឬទេ ?

ចម្លើយ : អ្នកបោះឆ្នោតត្រូវទៅបង្ហាញខ្លួននិងត្រូវបោះឆ្នោត ដោយខ្លួនឯងផ្ទាល់នៅការិយាល័យ បោះឆ្នោត ដែលខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ហើយត្រូវបង្ហាញឯកសារបញ្ជាក់ អត្តសញ្ញាណ របស់ខ្លួនដល់មន្ត្រីការិយាល័យបោះឆ្នោត។

សំណួរ៣៣: តើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ ផ្តើមពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

ចម្លើយ : ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្តើម ពីម៉ោង៧:០០ព្រឹក រហូតដល់ម៉ោង ១៥:០០នាទី រសៀល។ អ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត

ហើយមានវត្តមាននៅក្នុង ការិយាល័យបោះឆ្នោត ឬបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅម៉ោង ១៥:០០នាទី អាចបោះឆ្នោតក្រោយ ម៉ោង ១៥:០០នាទីបាន។

សំណួរ៣៨: នៅថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តើអ្នកបោះឆ្នោតណាខ្លះដែលត្រូវបានផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេ ?

ចម្លើយ : នៅថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអ្នកបោះឆ្នោតដែលត្រូវបានផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេមានអ្នកបោះឆ្នោតដែលជា៖

- អ្នកមានវ័យចំណាស់
- ស្ត្រីមានផ្ទៃពោះ
- ស្ត្រីមានកូនតូច
- អ្នកមានជំងឺ
- ជនមានពិការភាព និងអ្នកជំនួយជានីតិជន។

សំណួរ៣៩: តើអ្នកបោះឆ្នោតម្នាក់ៗ មានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាខ្លះ ហើយអ្នកបោះឆ្នោតត្រូវធ្វើដូចម្តេចខ្លះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ?

ចម្លើយ : អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា២ប្រភេទ៖

ទី១៖ អ្នកបោះឆ្នោតទទួលយកសន្លឹកឆ្នោតដែលមានពណ៌លឿងពីលេខាធិការ សម្រាប់ការ

បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ បន្ទាប់មកអ្នកបោះឆ្នោតត្រូវដើរតម្រង់ទៅរកបន្ទប់សម្ងាត់ទី១ដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសគណបក្សណាមួយដែលខ្លួនពេញចិត្ត។ អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម រួចយកសន្លឹកឆ្នោតនោះ ទៅស៊កចូលក្នុងហិបឆ្នោតទី១ដែលស្ថិតនៅលើតុអនុប្រធាន(បែរផ្នែកដែលមានបោះត្រាសម្ងាត់ទៅរកអនុប្រធាន)។

ទី២៖ អ្នកបោះឆ្នោត ត្រូវរង់ចាំអនុប្រធានប្រគល់សន្លឹកឆ្នោតពណ៌សមួយសន្លឹកទៀតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត។ អ្នកបោះឆ្នោតត្រូវដើរតម្រង់ទៅបន្ទប់សម្ងាត់ទី២ ដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសគណបក្សណាមួយ ដែលខ្លួន ពេញចិត្ត។ អ្នកបោះឆ្នោតត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម រួចយកសន្លឹកឆ្នោតនោះ ទៅស៊កចូលក្នុងហិបឆ្នោតទី២ដែលស្ថិតនៅលើតុសមាជិកទី១ (បែរផ្នែកដែលមានបោះត្រាសម្ងាត់ទៅរកសមាជិកទី១) និងត្រូវយល់ព្រមឱ្យសមាជិកទី១ជ្រលក់ម្រាមដៃរបស់ខ្លួនទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ សម្រាប់បង្ការមិនឱ្យមានការបោះឆ្នោតលើសពីមួយដង។

សំណួរ៣៦: តើអ្នកបោះឆ្នោតអាចស្នើសុំជំនួយពីជនណាម្នាក់ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតឱ្យជួយគាត់ក្នុងការបោះឆ្នោតបានដែរឬទេ?

ចម្លើយ : អ្នកបោះឆ្នោតមិនអាចស្នើសុំជំនួយពីជនណាម្នាក់ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតបានឡើយ។

សំណួរ៣៧: ប្រសិនបើអ្នកបោះឆ្នោតជាជនមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន តើគាត់ត្រូវធ្វើដូចម្តេចដើម្បីបោះឆ្នោតបាន?

ចម្លើយ : អ្នកបោះឆ្នោតជាជនមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត។

សំណួរ៣៨: តើភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោតអាចជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានដែរឬទេ?

ចម្លើយ : ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោតមិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតឡើយ ទោះបីអ្នកបោះឆ្នោតស្នើសុំឱ្យជួយក៏ដោយ។

សំណួរ៣៩: តើអ្នកបោះឆ្នោត ឬអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោតអាចប្រើទូរស័ព្ទដៃឬឧបករណ៍ផ្សេងៗដែលអាចថតរូបបានដែរឬទេ?

ចម្លើយ : អ្នកបោះឆ្នោត ឬអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត មិនអាចប្រើទូរស័ព្ទដៃ ឬ ឧបករណ៍ផ្សេងៗដែលអាចថតរូបបាន ឬ និង ធ្វើសកម្មភាពទាំងឡាយណាដែលរំលោភ លើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតបានឡើយ។

សំណួរ៤០: តើកាលបរិច្ឆេទនៃការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រព្រឹត្តទៅនៅពេលណា ?

ចម្លើយ: កាលបរិច្ឆេទនៃការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ (ករណីគ្មានការបោះឆ្នោតសាជាថ្មី)។

គ.ជ.ប

# គំរូសកម្មភាពក្នុងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី
# ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩




បោះពុម្ពដោយ គ.ជ.ប ឆ្នាំ២០១៩